*[សូមផ្ទៀងផ្ទាត់ តាមការអាន]*

# សុន្ទរកថា
# អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន
## ឧបនាយករដ្ឋមន្ត្រី, រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
## ថ្លែងក្នុងពិធី
## ប្រកាសដាក់ឱ្យអនុវត្តនីតិវិធីចំណាយថវិកាចរន្ត ដែលមិនមានធានាចំណាយដោយឡែក តាម FMIS ទាំងស្រុង, ពង្រីកការដាក់ឱ្យប្រើប្រាស់ FMIS នៅការដ្ឋានថ្មី, ពង្រីកការដាក់ឱ្យប្រើប្រាស់ FMIS Portal ជំនាន់ទី ១ ដែលនៅសេសសល់ នៅរដ្ឋបាលថ្នាក់ក្រោមជាតិ និង ពង្រីកសន្ទានកម្មទិន្នន័យ រវាង FMIS ជាមួយប្រព័ន្ធគ្រប់គ្រងមន្ត្រីរាជការរបស់ក្រសួងមុខងារសាធារណៈ

សណ្ឋាគារហៃយ៉ាត់ រីជិនស៊ី ភ្នំពេញ, ថ្ងៃព្រហស្បតិ៍ ទី ៦ ខែ កក្កដា ឆ្នាំ ២០២៣

- លោកស្រី **យូតសារ៉ាណា ម៉ាម៉ា** នាយិកាធនាគារអភិវឌ្ឍន៍អាស៊ី ប្រចាំព្រះរាជាណាចក្រកម្ពុជា;
- ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី, ថ្នាក់ដឹកនាំ, តំណាងក្រសួង-ស្ថាប័ន និងដៃគូអភិវឌ្ឍន៍;
- ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី, សមាជិក, សមាជិកានៃអង្គពិធី, ជាទីមេត្រី!

ថ្ងៃនេះ, ខ្ញុំមានសេចក្តីសោមនស្សជាអនេក ដោយបានមកចូលរួមជាអធិបតី ក្នុងពិធីប្រកាសដាក់ឱ្យអនុវត្ត នូវការងារដ៏មានសារៈសំខាន់មួយចំនួន ក្នុងក្របខណ្ឌនៃគម្រោង

*[សូមផ្ទៀងផ្ទាត់ តាមការអាន]*

FMIS រួមមាន ៖ (១).**ដាក់ឱ្យអនុវត្តនីតិវិធីចំណាយថវិកាចរន្ត ដែលមិនមានជានាចំណាយដោយឡែក តាម FMIS ទាំងស្រុង;** (២).**ពង្រីកការដាក់ឱ្យប្រើប្រាស់ FMIS នៅការដ្ឋានថ្មី;** (៣).**ពង្រីកការដាក់ឱ្យប្រើប្រាស់ FMIS Portal ជំនាន់ទី ១ ដែលនៅសេសសល់ នៅរដ្ឋបាលថ្នាក់ក្រោមជាតិ;** និង (៤).**ពង្រីកសន្ទានកម្មទិន្នន័យ រវាង FMIS និង ប្រព័ន្ធគ្រប់គ្រងមន្ត្រីរាជការរបស់ក្រសួងមុខងារសាធារណៈ** ។ ខ្ញុំសូមសម្តែងនូវការស្វាគមន៍យ៉ាងកក់ក្តៅចំពោះវត្តមានឯកឧត្តម, លោកជំទាវ, លោក, លោកស្រី, ថ្នាក់ដឹកនាំ, មន្ត្រីរាជការ, តំណាងដៃគូអភិវឌ្ឍន៍, ភ្ញៀវជាតិ និង អន្តរជាតិ, ដែលបានឆ្លៀតពេលចូលរួមក្នុងពិធីនាថ្ងៃនេះ, ទាំងនៅទីនេះផ្ទាល់ និង នៅតាមប្រព័ន្ធវីដេអូ អនឡាញ ។

ខ្ញុំសូមថ្លែងអំណរគុណ **ឯកឧត្តមបណ្ឌិតសភាចារ្យ ហ៊ាន សាហ៊ីប** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី, រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, និង ជាប្រធានក្រុមការងារគ្រប់គ្រងគម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS), ដែលបានផ្តល់នូវរបាយការណ៍សង្ខេប អំពីទិដ្ឋភាពទូទៅ និង លទ្ធផលការងារដែលសម្រេចបាន ក្នុងក្របខណ្ឌនៃការអនុវត្តគម្រោង FMIS ។ ជាមួយគ្នានេះ, ខ្ញុំក៏សូមថ្លែងអំណរគុណផងដែរ ចំពោះលោកស្រី **យូតសារណា ម៉ាម៉ា**, នាយិកាធនាគារអភិវឌ្ឍន៍អាស៊ីប្រចាំព្រះរាជាណាចក្រកម្ពុជា, ដែលបានផ្តល់នូវមតិចំណាប់អារម្មណ៍ របស់តំណាងដៃគូអភិវឌ្ឍន៍ទាំងអស់ លើការអនុវត្តគម្រោង FMIS នៅកម្ពុជា ។ របាយការណ៍របស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ ប្រធានក្រុមការងារ** បានឆ្លុះបញ្ចាំងឱ្យឃើញថា, ក្នុងរយៈពេលដ៏ខ្លី, ក្រុមការងារគ្រប់គ្រងគម្រោង FMIS សម្រេចបាននូវលទ្ធផលការងារធំៗជាច្រើន បន្ថែមទៀត គួរឱ្យកត់សម្គាល់ និង បានបង្ហាញថា យើងកំពុងធ្វើដំណើរស្របតាម **ផែនការពង្រីកការអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ជំហានទី ៣ ឆ្នាំ ២០២១-២០២៥,** បន្ថែមពីលើសមិទ្ធផលការងារដែលសម្រេចបាន នាពេលកន្លងទៅថ្មីៗ ដែលខ្ញុំបានចូលរួមជាអធិបតី នៅក្នុងពិធីប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការ កាលពីថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០២៣ ។

## ***ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី!***

ជារួម, សមិទ្ធផលដែលកើតចេញពីគម្រោង FMIS ចាប់ផ្តើមតាំងពីជំហានទី ១ រហូតដល់បច្ចុប្បន្ន រួមមាន ៖

*[សូមផ្ទៀងផ្ទាត់ តាមការអាន]*

**ទី១).**ការដាក់ឱ្យប្រើប្រាស់មុខងារស្នូលនៃ FMIS ជាបន្តបន្ទាប់ រហូតដល់មានការដ្ឋានសរុបចំនួន **១៦៩,** រាប់បញ្ចូលទាំងអគ្គនាយកដ្ឋានគន្លឹះរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, អង្គភាពទទួលបន្ទុកហិរញ្ញវត្ថុនៃក្រសួង-ស្ថាប័នទាំងអស់, អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញនៅថ្នាក់កណ្តាល, រដ្ឋបាលរាជធានី-ខេត្ត ទាំង **២៥,** មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រាជធានី-ខេត្ត ទាំង **២៥**, និង រតនាគាររាជធានី-ខេត្ត ទាំង **២៥**;

**ទី២).**ការដាក់ឱ្យប្រើប្រាស់ FMIS Portal ជំនាន់ទី ១ នៅរដ្ឋបាលក្រុង-ស្រុក និង ឃុំ-សង្កាត់ ចំនួន ៨០២;

**ទី៣).**ការដាក់ឱ្យអនុវត្តនីតិវិធីទូទាត់ចំណាយបៀវត្ស, ចំណាយទឹក-ភ្លើង និង ចំណាយបន្ទុកបុគ្គលិកផ្សេងទៀត តាម FMIS ទាំងស្រុង នៅតាមក្រសួង-ស្ថាប័ន ចំនួន **៣៤** និង អនុវត្តនីតិវិធីចំណាយថវិកាចរន្តតាម FMIS ទាំងស្រុង នៅតាមក្រសួង-ស្ថាប័ន ចំនួន ៨;

**ទី៤).**ការដាក់ឱ្យប្រើប្រាស់មុខងារសន្ទានកម្ម ផ្លាស់ប្តូរទិន្នន័យជាមួយប្រព័ន្ធខាងក្រៅ ចំនួន **១៦** រួមជាមួយនឹងការអភិវឌ្ឍ និង ការដាក់ឱ្យប្រើប្រាស់មុខងារលទ្ធកម្មពេញលេញ និង មុខងាររៀបចំផែនការថវិកានៅតាមការដ្ឋាន ដែលបានអនុវត្តមុខងារស្នូលនៃ FMIS រួចហើយ ។

បើទោះបីជាសមិទ្ធផលជាច្រើន ត្រូវបានដាក់ឱ្យអនុវត្ត និង ប្រើប្រាស់ជាផ្លូវការ ជាបន្តបន្ទាប់, ដូចខ្ញុំបានគូសបញ្ជាក់ខាងលើក្តី, ក៏ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នៅតែបន្តធ្វើការងារយ៉ាងសកម្ម ដោយបានក្លាយជាទម្លាប់នៃការធ្វើការជាប់ជាប្រចាំឥតឈប់, ឆ្ពោះទៅមុខជានិច្ច, ប្រកបដោយភាពប្រុងប្រយ័ត្នខ្ពស់, សំដៅជានាសម្រេចឱ្យបាននូវគោលដៅគន្លឹះដែលត្រូវបានដាក់ចេញ ពោលគឺការបន្តពង្រីកវិសាលភាពនៃការប្រើប្រាស់ FMIS នៅទូទាំងប្រទេស និង ការពង្រីកវិសាលភាពនៃការអនុវត្តនីតិវិធីតាម FMIS ទាំងស្រុង នៅតាមគ្រប់ការដ្ឋានដែលបានប្រើប្រាស់ FMIS រួចហើយ ។

ជាក់ស្តែង, នាថ្ងៃនេះ, ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, តាមរយៈក្រុមការងារគ្រប់គ្រងគម្រោង FMIS, សម្រេចបាននូវសមិទ្ធផលគោលដៅធំៗចំនួន ៤ បន្ថែមទៀត នៅក្នុងក្របខណ្ឌផែនការសកម្មភាពរួម នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី ៤ និង ផែនការពង្រីកការអនុវត្តគម្រោង FMIS ជំហានទី ៣, ដែលខ្ញុំសូមគូសរំលេច ដូចខាងក្រោម៖

*[សូមផ្ទៀងផ្ទាត់ តាមការអាន]*

**ទី១).**បញ្ចប់ការរៀបចំ និង អភិវឌ្ឍ FMIS ដើម្បីដាក់ឱ្យ**អនុវត្តនីតិវិធីចំណាយថវិកាចរន្ត ដែលមិនមានធានាចំណាយដោយឡែក តាម FMIS ទាំងស្រុង សម្រាប់ក្រសួង ចំនួន ៧** រួមមាន ៖ ក្រសួងសុខាភិបាល, ក្រសួងផែនការ, ក្រសួងអប់រំ យុវជន និង កីឡា, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ, ក្រសួងសាធារណការ និង ដឹកជញ្ជូន, ក្រសួងមុខងារសាធារណៈ និង ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍ ។

**ទី២).**បញ្ចប់ការរៀបចំ និង អភិវឌ្ឍបន្ថែម លើមុខងារស្នូលនៃ FMIS **ដើម្បីដាក់ឱ្យប្រើប្រាស់នៅតាមគ្រឹះស្ថានសាធារណៈរដ្ឋបាល ចំនួន ៤** ដំបូង រួមមាន ៖ គ្រឹះស្ថានអង្គរ, រាជបណ្ឌិត្យសភាកម្ពុជា, វិទ្យាស្ថានស្រាវជ្រាវ និង អភិវឌ្ឍន៍កសិកម្ម និង មជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី «**តេជោ**» ។

**ទី៣).**បញ្ចប់ការរៀបចំ និង អភិវឌ្ឍកម្មវិធី FMIS Portal ជំនាន់ទី ១ ដើម្បី**ដាក់ឱ្យប្រើប្រាស់នៅតាមរដ្ឋបាលក្រុង-ស្រុក និង ឃុំ-សង្កាត់ ដែលនៅសេសសល់ទាំងអស់ ចំនួន ១ ០៣៧**, ក្នុងនោះ, រួមមាន ៖ រដ្ឋបាលក្រុង ចំនួន **២២**, រដ្ឋបាលស្រុក ចំនួន **២៦**, រដ្ឋបាលសង្កាត់ ចំនួន **២១៨** និង រដ្ឋបាលឃុំ ចំនួន **៧៧១** ។

**ទី៤).**បញ្ចប់ការរៀបចំ និង អភិវឌ្ឍមុខងារសន្ទានកម្ម រវាង FMIS និង ប្រព័ន្ធគ្រប់-គ្រងមន្ត្រីរាជការរបស់ក្រសួងមុខងារសាធារណៈ លើទិន្នន័យបៀវត្សមន្ត្រីរាជការស៊ីវិល សម្រាប់ក្រសួង-ស្ថាប័ន ចំនួន **២២** បន្ថែមទៀត និង អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ ចំនួន **២** បន្ថែមលើក្រសួង-ស្ថាប័ន ចំនួន **៨** ដែលបានអនុវត្តមុខងារសន្ទាន-កម្មនេះ ប្រកបដោយជោគជ័យ ចាប់តាំងពីឆ្នាំ ២០២២ ។

## *ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី!*

ខ្ញុំពិតជាមានមោទកភាពយ៉ាងក្រៃលែង ដោយបានឃើញសមិទ្ធផលថ្មីៗទាំងនេះលេចចេញជារូបរាង នៅក្នុងក្របខណ្ឌនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់កម្ពុជា ។ ការណ៍នេះបានបង្ហាញឱ្យឃើញច្បាស់ ពីការខិតខំ និង ការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការកែទម្រង់ហិរញ្ញវត្ថុសាធារណៈ ។ ពិតណាស់ថា សមិទ្ធផលទាំងអស់នេះ បានកើតចេញពីការប្តេជ្ញាចិត្តខ្ពស់ និង ការខិតខំយ៉ាងមុះមុត ដោយឥតរាថយរបស់ថ្នាក់ដឹកនាំ និង មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, ជាពិសេស ការសម្របសម្រួល, ការគាំទ្រ និង ការយកចិត្តទុកដាក់ ពីសំណាក់ក្រុមការងារ

គ្រប់គ្រងគម្រោង FMIS គួបផ្សំនឹងការចូលរួមយ៉ាងសកម្ម ពីគ្រប់តួអង្គស្នូលនៅតាមក្រសួង-ស្ថាប័ននីមួយៗ ស្របតាមមាគ៌ាដឹកនាំដ៏ត្រឹមត្រូវ, ឆន្ទៈនយោបាយដ៏មុះមុត និងការតម្រង់ទិសដ៏ច្បាស់លាស់ និង វៃឆ្លាតបំផុត របស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា គឺ **សម្តេច-អគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**, ដែលជាអគ្គមគ្គុទេសក៍ដ៏ឆ្នើមបំផុតរបស់កម្ពុជា ។

កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺជាកម្មវិធីនយោបាយអាទិភាពមួយ របស់រាជរដ្ឋាភិបាលកម្ពុជា ដែលមានចក្ខុវិស័យប្រែក្លាយប្រព័ន្ធហិរញ្ញវត្ថុសាធារណៈកម្ពុជា ឆ្ពោះទៅកាន់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលផ្តោតលើលទ្ធផល ឬ សមិទ្ធកម្ម និងវិមជ្ឈការ ស្របតាមស្តង់ដា និង ឧត្តមានុវត្តន៍អន្តរជាតិ, ដែលក្នុងនោះ, FMIS ជាឧបករណ៍ស្នូល និង មិនអាចខ្វះបាន, សម្រាប់ជួយទ្រទ្រង់, គាំទ្រ និង ជំរុញដល់ការសម្រេចបាននូវគោលដៅនៃដំណាក់កាលនីមួយៗ របស់កម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈ, ជាពិសេសដំណាក់កាលគណនេយ្យភាពហិរញ្ញវត្ថុ, ដំណាក់កាលផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោ-បាយ និង ដំណាក់កាលគណនេយ្យភាពសមិទ្ធកម្ម ។

ផ្អែកតាមរបាយការណ៍ របស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ ហ៊ាន សាហ៊ីប** អំបាញ់មិញនេះ, ការអនុវត្តគម្រោង FMIS កំពុងតែស្ថិតនៅពាក់កណ្តាលនៃជំហានទី ៣ ហើយជំហានទី ៣ នេះគ្រោងនឹងបញ្ចប់នៅឆ្នាំ ២០២៥ ។ ទោះជាយ៉ាងនេះក្តី, ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នឹងមិនបញ្ចប់ការងារនេះត្រឹមហ្នឹងទេ ពោលគឺយើងនៅតែបន្តមហិច្ឆតាពង្រឹងសមត្ថភាពប្រព័ន្ធនេះ ដើម្បីប្រើប្រាស់ឱ្យអស់សក្តានុពល និង ឱ្យសមទៅនឹងតម្លៃវិនិយោគ ព្រមទាំងបន្តពង្រីកវិសាលភាពនៃការប្រើប្រាស់ FMIS រហូតដល់អង្គភាពអនុវត្តថវិកា និងអង្គភាពចំណាយថវិការដ្ឋ នៅគ្រប់ទីន្លែងទូទាំងប្រទេស, ជាពិសេស នឹងបន្តធ្វើវិមជ្ឈការការគ្រប់គ្រង និង ការអនុវត្តថវិកា ទៅដល់គ្រប់ក្រសួង-ស្ថាប័ន និង អង្គភាពអនុវត្តថវិកាទាំងអស់ រួមជាមួយនឹងការបន្តធ្វើបរិវត្តកម្មឌីជីថលថ្មីៗបន្ថែមទៀត ដើម្បីផ្សារភ្ជាប់មុខងារដែលមានស្រាប់ ទៅនឹងមុខងារថ្មីរបស់ FMIS ដែលនឹងត្រូវអភិវឌ្ឍ ដើម្បីប្រែក្លាយនីតិវិធីនៃការអនុវត្តការងារដោយដៃ និង ប្រើក្រដាស ទៅជានីតិវិធីតាមបែបឌីជីថលទាំងស្រុង ។ ទន្ទឹមនេះ, ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក៏បានប្តេជ្ញាចិត្តយ៉ាងមុតមាំ ក្នុងការធ្វើជាគំរូសម្រាប់ការអនុវត្តការងារថ្មី ដែលជាការងារកែទម្រង់ ឬ ការងារដែលមានការផ្លាស់ប្តូរ

នៅក្នុងក្របខណ្ឌនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីដកស្រង់បទពិសោធន៍ជាមុន, មុននឹងឈានទៅដល់ការដាក់ឱ្យអនុវត្តនៅតាមក្រសួង-ស្ថាប័ន ឬ អង្គភាពផ្សេងទៀត ។

ការពង្រីកវិសាលភាពនៃការប្រើប្រាស់ FMIS ជាមួយនឹងការពង្រីកវិសាលភាពនៃការអនុវត្តនីតិវិធីហិរញ្ញវត្ថុតាម FMIS ទាំងស្រុង គឺជាការចូលរួមចំណែកមួយ នៅក្នុងការធ្វើបរិវត្តកម្មឌីជីថលរបស់រាជរដ្ឋាភិបាល ស្របតាម **គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥** ។ ដូច្នេះ, **មន្ត្រីរាជការត្រូវត្រៀមលក្ខណៈឱ្យបានរួចរាល់ ក្នុងការរៀនសូត្របន្ថែម និង ចាប់យកឱ្យបាននូវការផ្លាស់ប្តូររបៀបធ្វើការងារថ្មី, បង្កើនភាពស៊ាំឱ្យបានលឿន និង តាមឱ្យទាន់កាលៈទេសៈនៃការវិវឌ្ឍសង្គម និង សេដ្ឋកិច្ចឌីជីថល** ។

ត្រង់ចំណុចនេះ, ខ្ញុំសូមរម្លឹកនូវឱវាទានុសាសន៍ដ៏ខ្លង់ខ្លស់ របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលតែងដាស់តឿនយើងទាំងអស់គ្នាជារឿយៗថា «**កែទម្រង់-រស់, មិនកែទម្រង់-ស្លាប់**»; «**គ្មានលទ្ធផលណាដែលបានមកដោយមិនមានការបង់ថ្លៃនោះទេ ហើយក៏គ្មានការកែទម្រង់ណា ដែលសម្រេចបានមកដោយមិនមានការលះបង់នោះដែរ**» ។ ក្នុងន័យនេះ, ខ្ញុំសង្ឃឹមថា ថ្នាក់ដឹកនាំ និង មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ ដែលមានតួនាទី និង ភារកិច្ច ក្នុងការបំពេញកិច្ចការគ្រប់គ្រងថវិកា និង ហិរញ្ញវត្ថុសាធារណៈ នឹងប្រឹងប្រែងលះបង់នូវប្រយោជន៍បុគ្គល ឬ ប្រយោជន៍ក្រុម ហើយបែមកគិតគូរប្តេជ្ញាចិត្ត ឱ្យបានមុតមាំតាមគំរូលះបង់ និង ប្រកបដោយវីរភាពដ៏អង់អាច របស់ **សម្តេចតេជោ នាយករដ្ឋមន្ត្រី** ដែលតែងតែតម្កល់ប្រយោជន៍ជាតិជាធំ ។ ខ្ញុំក៏សូមលើកទឹកចិត្តដល់មន្ត្រីរបស់យើង ឱ្យផ្លាស់ប្តូរផ្នត់គំនិត មកទទួលយកនូវបរិបទថ្មីនៃការផ្លាស់ប្តូររបៀបរបបបំពេញការងារ ព្រមទាំងខិតខំបំពេញភារកិច្ចរបស់ខ្លួនឱ្យបានត្រឹមត្រូវ ប្រកបដោយវិជ្ជាជីវៈ ដោយគិតពីប្រសិទ្ធភាពនៃការប្រើប្រាស់ថវិកាជាតិ និង «**តម្លៃនៃលុយ**» ដើម្បីលើកកម្ពស់គុណភាព និង ប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ ឱ្យបានកាន់តែប្រសើរឡើង ជាលំដាប់ ។

ឆ្លៀតឱកាសនេះ, ខ្ញុំសូមវាយតម្លៃខ្ពស់ ចំពោះការខិតខំរបស់ក្រុមការងារគ្រប់គ្រងគម្រោង FMIS ដែលដឹកនាំដោយ **ឯកឧត្តមបណ្ឌិតសភាចារ្យ ហ៊ាន សាហ៊ីប**, លេខាធិការដ្ឋានគ្រប់គ្រងគម្រោង FMIS និង អគ្គនាយកដ្ឋាននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលបានគាំទ្រ និង ចូលរួមសហការគ្នាជាធ្លុងមួយ នាពេលកន្លងមក ដោយសម្រេចបាននូវសមិទ្ធផលជាច្រើន ដូចបានរៀបរាប់ខាងលើ ។ ខ្ញុំក៏សូមថ្លែងអំណរគុណដល់គ្រប់ភាគី

ពាក់ព័ន្ធនៃក្រសួង-ស្ថាប័ន និង អង្គភាពនៅថ្នាក់មូលដ្ឋាន, ជាពិសេស ដៃគូអភិវឌ្ឍន៍ ដែលបានចូលរួមគាំទ្រ នាពេលកន្លងមក, ទាំងជាបច្ចេកទេស និង ជាហិរញ្ញប្បទាន ។ ខ្ញុំសូមលើកទឹកចិត្តដល់គ្រប់តួអង្គពាក់ព័ន្ធទាំងអស់ ឱ្យបន្តកិច្ចសហប្រតិបត្តិការជិតស្និទ្ធ ដោយឥតបង្អង់ ដើម្បីរួមគ្នា នាំកម្ពុជាឈានឆ្ពោះទៅរកភាពរីកចម្រើន និង វិបុលភាព នៅក្រោមម្លប់ដ៏ត្រជាក់នៃសុខសន្តិភាព ដែល **សម្តេចតេជោ នាយករដ្ឋមន្ត្រី** បាននាំមកជូនប្រទេសជាតិ និង ប្រជាជនកម្ពុជា ។

ជាទីបញ្ចប់, ខ្ញុំសូមប្រសិទ្ធពរជ័យជូនឯកឧត្តម, លោកជំទាវ, លោក, លោកស្រីទាំងអស់ប្រកបដោយសុខភាពល្អបរិបូរណ៍, មានសុភមង្គលក្នុងក្រុមគ្រួសារ និង សម្រេចបាននូវជោគជ័យក្នុងគ្រប់ភារកិច្ច ។

ក្នុងឱកាសដ៏វិសេសវិសាលនេះ, ខ្ញុំសូមប្រកាស៖

១). ដាក់ឱ្យអនុវត្តនីតិវិធីចំណាយថវិកាចរន្ត ដែលមិនមានជានាចំណាយដោយឡែក តាម FMIS ទាំងស្រុង សម្រាប់ក្រសួង-ស្ថាប័ន ចំនួន **៧**;

២). ដាក់ឱ្យប្រើប្រាស់ FMIS នៅតាមគ្រឹះស្ថានសាធារណៈរដ្ឋបាល ចំនួន **៤**;

៣). ដាក់ឱ្យប្រើប្រាស់កម្មវិធី FMIS Portal ជំនាន់ទី ១ នៅតាមរដ្ឋបាលក្រុង-ស្រុក និង ឃុំ-សង្កាត់ ដែលនៅសេសសល់ទាំងអស់ នៅទូទាំងប្រទេស;

៤). ដាក់ឱ្យអនុវត្តមុខងារសន្ធានកម្ម រវាង FMIS និង ប្រព័ន្ធគ្រប់គ្រងទិន្នន័យបៀវត្សមន្ត្រីរាជការស៊ីវិលសម្រាប់ក្រសួង-ស្ថាប័ន ចំនួន **២២** បន្ថែម; និង

៥). បន្ថែមលើនេះ, ខ្ញុំក៏សូមប្រកាសដាក់ឱ្យអនុវត្តគម្រោង FMIS សម្រាប់រដ្ឋបាលក្រុង-ស្រុក ចំនួន **៤៤** ដើម្បីត្រៀមបន្តប្រើប្រាស់ជាផ្លូវការ នៅក្នុងឆ្នាំ ២០២៤ ខាងមុខ **ចាប់ពីពេលនេះតទៅ ៕**

***សូមអរគុណ!***